# រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ

ស្នាក់ការលេខ ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ: 023 72 40 46/ 023 43 05 41/ 023 43 01 79
គេហទំព័រ : www.ppwsa.com.kh
អ៊ីមែល : admin@ppwsa.com.kh

# ការផ្គត់ផ្គង់ទឹកស្អាត

| | |
|---|---|
| ឈ្មោះសេវា | ការផ្គត់ផ្គង់ទឹកស្អាត |
| ក្រសួង/ស្ថាប័ន<br>ផ្តល់សេវា | **រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ**<br>- អាស័យដ្ឋាន : ស្នាក់ការលេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ( ខាងជើងរាជាយស្ម័យានកម្ពុជា )<br>- ទូរស័ព្ទ : 023 72 40 46/ 023 43 05 41/ 023 43 01 79<br>- គេហទំព័រ : www.ppwsa.com.kh<br>- អ៊ីមែល : admin@ppwsa.com.kh |
| គោលបំណង<br>នៃការផ្តល់សេវា | ផលិត និងចែកចាយទឹកស្អាតសំរាប់ប្រើប្រាស់ ជូនដល់ប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ ទីប្រជុំជនជុំវិញរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្ត កណ្តាលជាប់នឹងរាជធានីភ្នំពេញ |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ ០៦៩៦/០៣ រកម ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពី លក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ<br>• អនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពី ការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| អតិថិជនដែលមាន<br>សិទ្ធទទួលសេវា | ជនជាតិខ្មែរ ឬ ជនជាតិបរទេស ឬ នីតិបុគ្គល |
| ស្តង់ដាសេវា | ក. <u>ការទទួលយកសេវា</u><br>• <u>ឈ្មោះអង្គភាព</u><br>- ជាភាសារជាតិ : រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ( រ.ទ.ស.ភ )<br>- ជាភាសារអន្តរជាតិ : Phnom Penh Water Supply Authority ( PPWSA )<br>• <u>ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ</u><br>- **ស្នាក់ការកណ្តាល** : អាសយដ្ឋានលេខ ៤៥,ផ្លូវ១០៦, សង្កាត់ស្រះចក ខណ្ឌដូនពេញ ស្ថិតនៅកណ្តាលរាជធានីភ្នំពេញ ( ខាងជើងរាជាយស្ម័យានកម្ពុជា )<br>. លេខទូរស័ព្ទទំនាក់ទំនង : 023 72 40 46/ 023 43 05 41 /023 43 01 79<br>. គេហទំព័រ : www.ppwsa.com.kh<br>. អ៊ីមែល : admin@ppwsa.com.kh<br> |

- **អាងតំកល់ទឹកជាយក្រុងចំនួន ៣ កន្លែង** :
  - <u>អាងតំកល់ទឹកក្បាលដំរី</u> : អាសយដ្ឋានផ្លូវលេខ១០៥K ភូមិក្បាលដំរី សង្កាត់កាកាប ខណ្ឌដង្កោ ក្រុងភ្នំពេញ (ទល់មុខព្រលានយន្តហោះភ្នំពេញ)
  - <u>អាងតំកល់ទឹកត្រពាំងថ្លឹង</u> : អាសយដ្ឋានភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ
  - <u>អាងតំកល់ទឹកច្រាំងចំរេះ</u> : អាសយដ្ឋានផ្លូវលេខ ១០៨R សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
- **សាខាអាជីវកម្មក្រុងតាខ្មៅ** : អាសយដ្ឋានផ្លូវលេខ ១២០៦ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ
- **រោងចក្រផលិតទឹកស្អាតនិរោធ** : អាសយដ្ឋាន: ផ្លូវជាតិលេខ ១ ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ

- <u>ម៉ោងបំពេញការងារ</u> : ម៉ោង ០៨:០០ ដល់ម៉ោង ១៦:៣០ (មិនមានការឈប់សំរាកពេលថ្ងៃត្រង់ឡើយ) រៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ។
  - ចំពោះផ្នែកបេឡាទទួលប្រាក់ក្នុងអង្គភាព ចាប់ផ្តើការពីម៉ោង ០៧ : ៣០ ដល់ម៉ោង ១៦ : ០០ រសៀល
  - ចំពោះផ្នែកបេឡាទទួលប្រាក់សាខាអាជីវកម្មក្រុងតាខ្មៅ, រោងចក្រ ផលិតទឹកស្អាតនិរោធ និងអាងតម្កល់ទឹកទាំង ៣ កន្លែង ចាប់ផ្តើការ ពីម៉ោង ០៧: ៣០ នាទី ដល់ ១៥:០០ នាទី

- <u>វត្តមានសេវាជួរមុខ</u> : គ្រប់ពេលវេលា ក្នុងម៉ោងបំពេញការងារចាប់ពីម៉ោង ០៨ :០០ ដល់ម៉ោង ១៦ :៣០ រសៀល (មិនមានការឈប់សំរាកពេលថ្ងៃត្រង់ឡើយ )

❖ **លក្ខខណ្ឌ និងនីតិវិធីក្នុងការផ្តល់សេវា**

- <u>សេវាតបណ្តាញចូលផ្ទះ</u> :

**ក-<u>ចំពោះអតិថិជនទូទៅ:</u>**

១-ត្រូវមកទំនាក់ទំនងយកពាក្យសុំសិទ្ធិជាវទឹក ពីក្រុមព័ត៌មានរបស់ការិយាល័យបណ្តាញចូលផ្ទះ នៃនាយកដ្ឋានអាជីវកម្មដែលផ្តល់ជូនដោយឥតគិតថ្លៃ ឬអាច Download តាមរយៈគេហទំព័ររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ www.ppwsa.com.kh ។

២-ក្រោយពីបំពេញឯកសារ(ចំនួន ០២ច្បាប់) ខាងលើរួច អតិថិជនត្រូវយកមកដាក់នៅក្រុមព័ត៌មានការិយាល័យបណ្តាញចូលផ្ទះដដែលដោយភ្ជាប់មកជាមួយពាក្យសុំនេះគឺ ៖

- ច្បាប់ចម្លងប័ណ្ណកម្មសិទ្ធិ ឬលិខិតមានតំលៃប្រហាក់ប្រហែល ចំនួន ០២ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំចំនួន ០២ ច្បាប់

- លិខិតអនុញ្ញាតឱ្យជីកផ្លូវដី ឬចិញ្ចើមផ្លូវរបស់សាលាសង្កាត់ ចំនួន ០១ ច្បាប់
- សូមសាមីខ្លួន ដែលមានឈ្មោះក្នុងពាក្យសុំជាវទឹកអញ្ជើញមកដាក់ពាក្យ និងបង់ប្រាក់ដោយផ្ទាល់ ។

៣-ក្រោយពីទទួលបានសំណុំពាក្យសុំសិទ្ធិជាវទឹកគ្រប់គ្រាន់ពីអតិថិជន រួចហើយក្រុមព័ត៌មាន ត្រូវណាត់ថ្ងៃចុះវាស់វែងជូនអតិថិជន ដើម្បីត្រៀមសហការ **យ៉ាងយូរបំផុតរយៈ ៣ ថ្ងៃ (ថ្ងៃធ្វើការងារ)** ក្រោយថ្ងៃទទួលពាក្យ

៤- ភ្នាក់ងារវាស់វែងត្រូវចុះវាស់វែងតាមថ្ងៃកំណត់ របស់ក្រុមព័ត៌មាន ដែលបានណាត់ជួបជាមួយអតិថិជន។

៥-ភ្នាក់ងារវាស់វែងត្រូវផ្ដល់ព័ត៌មានជូនអតិថិជនជ្រាប អំពីថ្លៃសិទ្ធិជាវទឹក ដែលត្រូវបង់ប្រាក់ និងថ្ងៃដែលត្រូវអញ្ជើញមកបង់ប្រាក់ ៖

**ក**-ចំពោះបណ្ដាញស្តង់ដា ដែលមាននាឡិកាស្ទង់ទំហំ **១៥ម.ម** និងមានប្រវែង **មិនលើសពី ១០ ម៉ែត្រ** ហើយគ្មានការជីកកាត់ផ្លូវកៅស៊ូ ឬបេតុង ។ ព័ត៌មាននេះត្រូវបានផ្ដល់ជូនអតិថិជនភ្លាមក្រោយពេលវាស់វែងរួច នូវតម្លៃសេវារួមមាន:

| | | |
|---|---|---|
| +តម្លៃបណ្ដាញ | = | ៣៦៥,៥០០ រៀល |
| +VAT ១០% | = | ៣៦,៥៥០ រៀល |
| +ប្រាក់កក់ | = | ៧៥,៤៨០ រៀល |
| +ទឹកប្រាក់បង្គ្រប់ | = | ២០ រៀល |
| **<u>សរុបរួម</u>** | **=** | **<u>៤៧៧,៥៥០ រៀល</u>** |

**ខ**-ចំពោះបណ្ដាញដែលមានប្រវែងលើសពី ១០ ម៉ែត្រ ឬបណ្ដាញ ដែលត្រូវសុំបង់រំលស់ថ្លៃសិទ្ធិជាវទឹក និងឧបត្ថម្ភធន ឬបណ្ដាញ ដែលមានតម្រូវការនាឡិកាស្ទង់ ទំហំធំជាង ១៥ មម។ ព័ត៌មាននេះត្រូវ បានផ្ដល់ជូនអតិថិជន ក្រោយការត្រួតពិនិត្យ និងសំរេចជា គោលការណ៍ របស់ថ្នាក់ដឹកនាំអង្គភាព។

**គ**-ចំពោះបណ្ដាញដែលត្រូវជីកកាត់ ផ្លូវកៅស៊ូ ឬបេតុង : ព័ត៌មានខាងលើនេះ ត្រូវបានផ្ដល់ជូនអតិថិជន ក្រោយពេលដែលអតិថិជនបានសុំច្បាប់អនុញ្ញាតជីកផ្លូវរួច ។ ( **ឧបសម្ព័ន្ធ ២** )

៦-អតិថិជនត្រូវអញ្ជើញមកបង់ប្រាក់ថ្លៃសិទ្ធិជាវទឹកដោយផ្ទាល់នៅការិយាល័យបណ្ដាញចូលផ្ទះ ក្រោយទទួលបានព័ត៌មានពីភ្នាក់ងារវាស់។

៧-ក្រោយការបង់ប្រាក់ថ្លៃសិទ្ធិជាវទឹករួចភ្លាម អតិថិជនត្រូវចុះកិច្ចសន្យា ជាវទឹកនៅការិយាល័យបណ្ដាញចូលផ្ទះ និងទទួលការណាត់ថ្ងៃចុះធ្វើបណ្ដាញ។

៨- ជាងបណ្ដាញត្រូវចុះដឹកតបណ្ដាញ ជូនអតិថិជនតាមពេលកំណត់ **យ៉ាងយូរបំផុតរយៈ ៣ថ្ងៃ (ថ្ងៃធ្វើការងារ)** ក្រោយការបង់ប្រាក់ថ្លៃសិទ្ធិជាវទឹករួចនិងធ្វើកំណត់ហេតុប្រគល់-ទទួលជាមួយអតិថិជនក្រោយពេលបញ្ចប់ការងារ

**ខ-<u>ចំពោះអតិថិជនក្រីក្រ</u>**

សម្រាប់ប្រជាពលរដ្ឋក្រីក្រ ដែលត្រូវសុំគោលការណ៍បង់រំលស់ ឬឧបត្ថម្ភធននៅតាមសហគមន៍ តំបន់ជាយក្រុងឆ្ងាយៗពាក្យសុំសិទ្ធិជាវទឹកនេះត្រូវបានមន្ត្រី រ.ទ.ស.ភ យកទៅចែកជូនដល់ប្រជាពលរដ្ឋដល់ទីតាំងផ្ទាល់តែម្តង។ ដោយក្នុងនោះប្រជាពលរដ្ឋត្រូវបំពេញឯកសារបន្ថែម ដូចខាងក្រោម៖

+ សំណើសុំបង់រំលស់ថ្លៃសិទ្ធិជាវទឹក
+ កិច្ចសន្យាស្តីពីការទូទាត់ថ្លៃសិទ្ធិជាវទឹកដោយបង់រំលស់ ( **ឧបសម្ព័ន្ធ ១** )

- <u>សេវាសុំប្ដូរឈ្មោះជាវទឹក</u>

**១**- អតិថិជនត្រូវមកទំនាក់ទំនងយកពាក្យសុំប្តូរឈ្មោះជាវទឹក ពីនិយោជិតរបស់ការិយាល័យចំណូលខណ្ឌណាមួយ(ត្រូវគ្នានឹងទីតាំងប្រើប្រាស់ទឹក) នៃនាយកដ្ឋានអាជីវកម្ម ដែលផ្តល់ជូនដោយឥតគិតថ្លៃ។

**២**-ឯកសារពាក្យសុំប្តូរឈ្មោះជាវទឹកមាន :

ក-ច្បាប់ចម្លងប័ណ្ណកម្មសិទ្ធិ ឬលិខិតមានតម្លៃប្រហាក់ប្រហែល ១ ច្បាប់ ចំនួន ០១ច្បាប់

ខ-ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនម្ចាស់កម្មសិទ្ធិ ១ ច្បាប់

គ-ច្បាប់ចម្លងវិក្កយបត្រថ្លៃទឹកចុងក្រោយ ០១ ច្បាប់

**៣**-ក្រោយពីបំពេញឯកសារខាងលើរួច អតិថិជនត្រូវយកមកដាក់នៅការិយាល័យចំណូលខណ្ឌដដែល ។

**៤**-ក្រោយពីទទួលបានសំណុំពាក្យសុំប្តូរឈ្មោះជាវទឹកគ្រប់គ្រាន់ ពីអតិថិជនរួច ការប្តូរឈ្មោះជាវទឹក អនុវត្តមិនលើសពី ០១ ថ្ងៃការងារ ។

- <u>សេវាសុំប្តូរអាសយដ្ឋានជាវទឹក</u>

១- អតិថិជនត្រូវមកទំនាក់ទំនងយកពាក្យសុំប្តូរឈ្មោះជាវទឹក ពីនិយោជិតរបស់ការិយាល័យចំណូលខណ្ឌណាមួយ (ត្រូវគ្នានឹងទីតាំងប្រើប្រាស់ទឹក) នៃនាយកដ្ឋានអាជីវកម្ម ដែលផ្តល់ជូនដោយឥតគិតថ្លៃ។

២- ឯកសារពាក្យសុំប្តូរអាសយដ្ឋានជាវទឹកមាន :

ក-ច្បាប់ចម្លងឯកសារអាជ្ញាធរមានសមត្ថកិច្ចបញ្ជាក់អាសយដ្ឋាន ១ ច្បាប់ ចំនួន ០១ ច្បាប់

ខ-ច្បាប់ចម្លងវិក្កយបត្រថ្លៃទឹកចុងក្រោយ ០១ ច្បាប់

៣- ក្រោយពីបំពេញឯកសារខាងលើរួច អតិថិជនត្រូវយកមកដាក់នៅការិយាល័យចំណូលខណ្ឌដដែល ។

៤- ក្រោយពីទទួលបាន សំណុំពាក្យសុំប្តូរអាសយដ្ឋានជាវទឹកគ្រប់គ្រាន់ ពីអតិថិជនរួច ការប្តូរអាសយដ្ឋានជាវទឹក អនុវត្តមិនលើសពី ០១ថ្ងៃការងារ

- <u>សេវាសុំដកប្រាក់កក់ធានាការប្រើប្រាស់ទឹក</u>

១- អតិថិជន ត្រូវមកទំនាក់ទំនងយកពាក្យសុំប្តូរឈ្មោះជាវទឹកពីនិយោជិតរបស់ការិយាល័យចំណូលខណ្ឌណាមួយ (ត្រូវគ្នានឹងទីតាំងប្រើប្រាស់ទឹក) នៃនាយកដ្ឋានអាជីវកម្ម ដែលផ្តល់ជូនដោយឥតគិតថ្លៃ។

២- ឯកសារពាក្យសុំដកប្រាក់កក់ធានាការប្រើប្រាស់ទឹកមាន :

ក-បង្កាន់ដៃបង់សិទ្ធិជាវទឹកច្បាប់ដើម ១ ច្បាប់

ខ-បង្កាន់ដៃបង់ប្រាក់កក់បន្ថែមច្បាប់ដើម (ប្រសិនបើមាន០១ ច្បាប់)

គ-ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ០១ ច្បាប់

ឃ-ច្បាប់ចម្លងវិក្កយបត្រថ្លៃទឹកចុងក្រោយ ០១ ច្បាប់

៣- ក្រោយពីបំពេញឯកសារខាងលើរួច អតិថិជនត្រូវយកមកដាក់នៅការិយាល័យចំណូលខណ្ឌដដែល ។

៤-ក្រោយពីទទួលបាន សំណុំពាក្យសុំដកប្រាក់កក់ធានាការប្រើប្រាស់ទឹកគ្រប់គ្រាន់ពីអតិថិជនរួចការដកប្រាក់កក់អាចផ្តល់ជូនអតិថិជនក្នុងរយៈពេលមិនលើសពី ០៧ ថ្ងៃការងារ ។

៥- ប្រសិនបើអ្នកមកដកប្រាក់កក់ពុំមែនជាម្ចាស់កម្មសិទ្ធិ ត្រូវមានលិខិតផ្ទេរសិទ្ធិពីម្ចាស់កម្មសិទ្ធិ និងអ្នកទទួលសិទ្ធិ។

៦-ប្រសិនបើអ្នកមកដកប្រាក់កក់ជាអ្នកជួលទីតាំង ត្រូវមានលិខិតអនុញ្ញាត

ពីម្ចាស់កម្មសិទ្ធិលើទីតាំង ឲ្យអ្នកជួលបើកប្រាក់កក់ ដែលខ្លួនបានបង់កន្លងមក និងអត្តសញ្ញាណប័ណ្ណរបស់ម្ចាស់កម្មសិទ្ធិនិងអ្នកជួលទីតាំង។

- <u>សេវាសុំវិក្កយបត្រទុតិយតា</u>

១- អតិថិជន ត្រូវមកទំនាក់ទំនងសុំវិក្កយបត្រទុតិយតាពីនិយោជិតរបស់ការិយាល័យចំណូលខណ្ឌណាមួយ(ត្រូវគ្នានឹងទីតាំងប្រើប្រាស់ទឹក)នៃនាយកដ្ឋានអាជីវកម្ម ដោយភ្ជាប់មកជាមួយ នូវវិក្កយបត្រថ្លៃទឹក ខែមុន។

២-អតិថិជនត្រូវបង់ប្រាក់១០០០រៀល(មួយពាន់រៀល) សម្រាប់វិក្កយបត្រ ១ សន្លឹក ។

៣-អតិថិជនអាចទទួលបានវិក្កយបត្រទុតិយតា ក្នុងរយៈពេលមិនលើស ពី ០១ ម៉ោងការងារ បន្ទាប់ពីពេលស្នើសុំ។

- <u>សេវាលើកនាឡិកាទឹក និងរំកិលទីតាំងនាឡិកាទឹកទំហំ ១៥ ម.ម.</u>

\+ អតិថិជនត្រូវមកទំនាក់ទំនងសុំលើកនាឡិកាទឹក និងរំកិលទីតាំងនាឡិកាទឹកនៅការិយាល័យទំនាក់ទំនងអតិថិជននៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដូចខាងក្រោមៈ

**១- <u>តម្លៃលើកនាឡិកាទឹក</u>**

| | |
|---|---|
| +តម្លៃ | = ៩០,២០០ រៀល |
| +VAT ១០% | = ៩,០២០ រៀល |
| **សរុបៈ** | **= ៩៩,២២០ រៀល** |

**២- <u>តម្លៃរំកិលទីតាំងនាឡិកាទឹក</u>**

| | |
|---|---|
| +តម្លៃ | = ១៤៣,៥០០ រៀល |
| +VAT ១០ % | = ១៤,៣៥០ រៀល |
| **សរុបៈ** | **= ១៥៧,៨៥០ រៀល** |

- <u>សេវាសុំប្លូរ៉ាន និងបើករ៉ាន</u>

\+ អតិថិជន ត្រូវមកទំនាក់ទំនងសុំប្លូរ៉ានថ្មី នៅការិយាល័យទំនាក់ទំនងអតិថិជន នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នូវតម្លៃដូចខាងក្រោមៈ

**<u>១-សេវាសុំប្លូរ៉ាន (ធម្មតា)</u>**

-ប្លូរ៉ាន ០១ ទំហំ ១៥ x ២១ មម. = ១៣,៨០០ រៀល តែបើ

-ប្លូរ៉ាន ០២ ទំហំ ១៥ x ២១ មម. = ១៨,៧០០ រៀល

**<u>២-សេវាសុំបើករ៉ាន (ធម្មតា)</u>**

-បំពង់ទំហំ ២៥ មម. ដល់ ៦៣ មម. = ៦០,៥០០ រៀល

- <u>សេវាទទួលប្រាក់ថ្លៃទឹក</u>

\+អតិថិជនអាចបង់ប្រាក់ថ្លៃប្រើប្រាស់ទឹកដោយផ្ទាល់នៅតាមទីតាំងណាមួយក៏បានដូចខាងក្រោម ៖

*-ស្នាក់ការកណ្តាល រ.ទ.ស.ភ* អាសយដ្ឋាន : លេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ

-ម៉ោងធ្វើការៈ ០៧: ៣០ នាទី ដល់ ១៦:០០ នាទី

-ទូរស័ព្ទលេខ : ០២៣ ៧២៤ ០៤៦

*-អាងតំកល់ទឹកក្បាលដំរី* អាសយដ្ឋាន : ផ្លូវលេខ១០៥K ភូមិ ក្បាលដំរី សង្កាត់កាកាប ខណ្ឌដង្កោ

-ម៉ោងធ្វើការ : ៧: ៣០ នាទី ដល់ ១៥:០០ នាទី

-ទូរស័ព្ទលេខ : ០១២ ៣១៩ ២៦៤

*-អាងតំកល់ទឹកត្រពាំងថ្លឹង* អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ

-ម៉ោងធ្វើការ : ៧: ៣០ នាទី ដល់ ១៥:០០ នាទី

| | |
|---|---|
| | -ទូរស័ព្ទលេខ : ០៩៧ ៦២៥ ៥៥៨៣<br>***-អាងតំកល់ទឹកប្រាំងចំរេះ:*** អាសយដ្ឋាន: ផ្លូវលេខ១០៨R សង្កាត់ ប្រាំងចំរេះ២ ខណ្ឌឫស្សីកែវ<br>-ម៉ោងធ្វើការ : ៧: ៣០ នាទី ដល់ ១៥:០០ នាទី<br>-ទូរស័ព្ទលេខ : ០១២ ៩២៥ ១៧៥<br>***-អាងតំកល់ទឹក ក្រុងតាខ្មៅ*** អាសយដ្ឋាន: ផ្លូវលេខ ១២០៦ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ<br>-ម៉ោងធ្វើការ : ៧: ៣០ នាទី ដល់ ១៥:០០ នាទី<br>-ទូរស័ព្ទលេខ : ០២៣ ៤២៥ ៧២៤<br>***-រោងចក្រផលិតទឹកស្អាត និរោធ*** អាសយដ្ឋាន: ផ្លូវជាតិលេខ ១ ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌមានជ័យ<br>-ម៉ោងធ្វើការ : ៧: ៣០ នាទី ដល់ ១៥:០០ នាទី<br>-ក្រៅពីការផ្តល់សេវាបង់ប្រាក់ដោយផ្ទាល់ រ.ទ.ស.ភ ក៏នៅមានសេវាទូទាត់ប្រាក់ថ្លៃប្រើប្រាស់ទឹករបស់អតិថិជន តាមរយៈប្រព័ន្ធធនាគារ និងប្រព័ន្ធទូរស័ព្ទដៃ របស់ធនាគារពាណិជ្ជកម្មអន្តរជាតិ (FTB), ធនាគារអេស៊ីលីដា (ACLEDA), ធនាគារកាណាឌីយ៉ា, WING និងប្រព័ន្ធទូរស័ព្ទក្រុមហ៊ុន Mobitel (Cell Card Cash) ផងដែរ។ |
| | ខ. **ព័ត៌មាន**<br>• ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ៖<br>១. ដំណើរការផលិតទឹកស្អាត<br>២. គុណភាពទឹក (អាចបរិភោគបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីនេ)<br>៣. អាសយដ្ឋានអង្គភាព រ.ទ.ស.ភ<br>៤. ទីកន្លែងទំនាក់ទំនងសួរព័ត៌មាន និងសុំពាក្យ - ដាក់ពាក្យសុំតបណ្តាញទឹក ព្រមទាំងបែបបទក្នុងដាក់ពាក្យសុំតបណ្តាញទឹក<br>៥. តំលៃតបណ្តាញសំរាប់ប្រជាពលរដ្ឋធម្មតា<br>៦. នយោបាយផ្តល់ឧបត្ថម្ភថ្លៃតបណ្តាញ សំរាប់ប្រជាពលរដ្ឋក្រីក្រ<br>៧. តំលៃទឹកតាមប្រភេទប្រើប្រាស់ និងរបៀបគណនាថ្លៃទឹកក្នុងវិក្កយប័ត្រ<br>៨. ព្រំដែននៃការទទួលខុសត្រូវលើបណ្តាញទឹក<br>៩. អំពីករណីដែលអតិថិជនត្រូវបង់ប្រាក់ ជូនអង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (នាឡិកាបាត់, នាឡិកាទឹកខូច, ខ្សែប្លុំបេដាច់វ៉ាន់ខូច និងជង្គង់ស្តង់ដាបាត់ ឬខូចដែលបង្កឡើងដោយអតិថិជន<br>១០. របៀបស្វែងរកបណ្តាញទឹកធ្លាយ ក្រោយនាឡិកាស្ទង់<br>១១. ឯកសណ្ឋានមន្ត្រីនិយោជិតកម្មករ រ.ទ.ស.ភ ដើម្បីចៀសវាងក្លែងបន្លំក្នុងគោលបំណងអាក្រក់<br>១២. លេខទូរស័ព្ទទំនាក់ទំនង: ០២៣ ៧២៥ ០៤៦/ ០២៣ ៤៣០ ៥៤១/ ០៩៧ ៧៧ ៣៣៣ ០៥ / ៧៧ ៣៣៣ ៤៥<br>( **ឧបសម្ព័ន្ធ ៥** )<br>• មធ្យោបាយផ្សព្វផ្សាយព័ត៌មានពីការផ្តល់សេវា ៖<br>ព័ត៌មានស្តីពីការផ្តល់សេវាត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈ ៖<br>១- ការប្រជុំផ្សព្វផ្សាយរួម នៅតំបន់ទើបផ្គត់ផ្គង់ទឹកថ្មី ទាំងនៅតំបន់ប្រជាពលរដ្ឋធម្មតា និងតំបន់ប្រជាពលរដ្ឋសហគមន៍អ្នកក្រីក្រ<br>២- បិទផ្សាយនៅលើក្តារព័ត៌មាន និងនៅកន្លែងផ្តល់សេវាផ្ទាល់ ដូចជាកន្លែងចែក-ដាក់ពាក្យសុំតបណ្តាញទឹក និងកន្លែងបង់ប្រាក់ |

| | |
|---|---|
| | ថ្លៃទឹក<br>៣- ផ្តល់ព័ត៌មាននៅគ្រប់បញ្ជរបង់ប្រាក់ ទាំងនៅស្នាក់ការកណ្តាល នៅតាមអាងតំល់ទឹក និងនៅសាខាអាជីវកម្មក្រុងតាខ្មៅ<br>៤- ទូរស័ព្ទទំនាក់ទំនង ២៤ ម៉ោង ដែលមាននៅលើខ្នងវិក្កយប័ត្រទឹក<br>៥- ផ្តល់ឯកសារព័ត៌មានជូនអតិថិជនបន្ទាប់ពីបង់ប្រាក់ថ្លៃតបណ្តាញរួច<br>៦- ព័ត៌មានតាមរយៈគេហទំព័រ រ.ទ.ស.ភ www.ppwsa.com.kh<br>៧- ព័ត៌មានតាមរយៈការធ្វើលិខិតឆ្លើយតបជាផ្លូវការ<br>៨- ព័ត៌មានតាមរយៈវិក្កយប័ត្របង់ប្រាក់ថ្លៃទឹក |
| | គ. **ភាពឆ្លើយតប**<br>• ការទទួល<br>១. អ្នកផ្តល់សេវារបស់អង្គភាព រ.ទ.ស.ភ តំរូវឱ្យមានអាកប្បកិរិយា រួសរាយ រាក់ទាក់ជាមួយអតិថិជនជានិច្ច<br>២. មន្ត្រី និយោជិត រ.ទ.ស.ភ មានឯកសណ្ឋាន ៤ ប្រភេទ ព្រមទាំងមានពាក់ស្លាកឈ្មោះ នៅលើហោប៉ៅអាវខាងឆ្វេង និងស្លាកសញ្ញា រ.ទ.ស.ភ នៅលើដៃអាវខាងឆ្វេង ដើម្បីឱ្យអតិថិជនងាយស្រួលទំនាក់ទំនងការងារ<br>៣. មានការិយាល័យម៉ាស៊ីនត្រជាក់ និងមានកៅអីអង្គុយរង់ចាំគ្រប់គ្រាន់ សំរាប់ទទួលអតិថិជនដែលមកដាក់ពាក្យសុំតបណ្តាញទឹក<br>៤. មានតុផ្តល់ព័ត៌មាន និងបញ្ជរសំរាប់ឱ្យអតិថិជនចូលមកបង់ប្រាក់ត្រឹមត្រូវ។<br>• យន្តការសម្របសម្រួលនិងការឆ្លើយតបចំពោះការលំបាករបស់អតិថិជន<br>· **សម្រួលដំណើរការដាក់ពាក្យសុំតបណ្តាញទឹករបស់អតិថិជនក្រីក្រ :**<br>សម្រួលដល់បងប្អូនប្រជាពលរដ្ឋក្រីក្រ នៅតំបន់ជាយក្រុង ក្នុងការធ្វើដំណើរមកទំនាក់ទំនងការងារតបណ្តាញទឹក (សុំពាក្យ-ដាក់ពាក្យ- បង់ថ្លៃតបណ្តាញ) ដល់ទីតាំងអង្គភាពផ្ទាល់ដែលមានចំងាយឆ្ងាយ ត្រូវចំណាយទាំងថវិកា និងពេលវេលាអស់ច្រើន នោះ រ.ទ.ស.ភ តែងតែបង្កើតស្នាក់ការបណ្តោះអាសន្ន នៅទីតាំងសហគមន៍ផ្ទាល់តែម្តង ដើម្បី :<br>- ផ្តល់ពាក្យសុំតបណ្តាញទឹកដោយឥតគិតថ្លៃ<br>- ទទួលពាក្យសុំតបណ្តាញទឹក<br>- ទទួលប្រាក់តបណ្តាញទឹក<br>- សម្ភាសន៍ប្រជាពលរដ្ឋ ដើម្បីផ្តល់កំរិតឧបត្ថម្ភធន<br>· **សម្រួលថ្លៃតបណ្តាញទឹកជូនប្រជាពលរដ្ឋក្រីក្រ :**<br>រ.ទ.ស.ភ មានគោលនយោបាយជួយដល់ប្រជាពលរដ្ឋក្រីក្រ ឱ្យទទួលបានបណ្តាញទឹកស្អាតប្រើប្រាស់ដោយផ្ទាល់ពីរដ្ឋ គោលនយោបាយនេះ អនុញ្ញាតឱ្យប្រជាពលរដ្ឋក្រីក្រ :<br>- បង់រំលស់ថ្លៃបណ្តាញ ១០ ខែ, ១៥ ខែ និង ២០ ខែ<br>- ឧបត្ថម្ភធនបញ្ចុះថ្លៃបណ្តាញ ៣០%, ៥០%, ៧០% និង ១០០%<br>តាមរយៈកម្មវិធីនេះ យើងបានជួយសន្សំថវិកាឲ្យប្រជាជនអ្នកប្រើប្រាស់ទឹក និងបានធ្វើឱ្យប្រសើរឡើង នូវសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងជួយសន្សំពេលវេលាសំរាប់ស្ត្រីមេផ្ទះ និងកុមារថែមទៀតផង។<br>· **សម្រួលដល់ការដាក់ពាក្យសុំតបណ្តាញទឹករបស់ប្រជាពលរដ្ឋទូទៅ :** |

| | |
|---|---|
| | ដើម្បីសម្រួលដល់ការលំបាករបស់បងប្អូនប្រជាពលរដ្ឋ ក្នុងការបំពេញបែបបទដាក់ពាក្យសុំតបណ្តាញទឹក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបង្កើតនូវ **បែបបទដំណើរការស្តង់ដាការងារ ( SOP ) តបណ្តាញទឹក**ជូនអតិថិជន ដែលបែបបទនេះបានកំណត់គ្រប់ជំហ៊ានការងារទាំងអស់រាប់ចាប់តាំងពី :<br>- ការចែកពាក្យជូនអតិថិជនដោយឥតគិតថ្លៃ<br>- ការជូនដំណឹងណាត់ជួបអតិថិជនដើម្បីវាស់វែងទីតាំង<br>- ការជូនដំណឹងឱ្យអតិថិជនមកបង់ប្រាក់ថ្លៃតបណ្តាញ និង<br>- ការចុះតបណ្តាញជូនអតិថិជនជាដើម ។ល។<br>រាល់ជំហានការងារនីមួយៗ សុទ្ធតែមានកំណត់ពេលវេលាយ៉ាងច្បាស់លាស់។ ឧទាហរណ៍ដូចជា **ការចុះតបណ្តាញត្រូវធ្វើឡើងមិនឱ្យលើសពី ៣ ថ្ងៃ (ថ្ងៃការងារ) បន្ទាប់ពីអតិថិជនបានបង់ប្រាក់រួចជាដើម**<br>· **សម្រួលការបង់ប្រាក់ថ្លៃប្រើប្រាស់ទឹក**<br>បានបង្កើតបេឡាទទួលប្រាក់ថ្លៃទឹក នៅតាមទីតាំងអាងតំកល់ទឹកតំបន់ជាយក្រុងទាំង ៣ កន្លែង , ការិយាល័យចំណូលតាខ្មៅ ១ កន្លែង និងរោងចក្រផលិតទឹកស្អាតនិរោធ ព្រមទាំងបង្កើតប្រព័ន្ធបង់ប្រាក់តាមធនាគារ និងប្រព័ន្ធទូរស័ព្ទដៃរបស់ធនាគារពាណិជ្ជកម្មអន្តរជាតិ (FTB), ធនាគារអេស៊ីលីដា (ACLEDA) , ធនាគារ កាណាឌីយ៉ា, WING និង ប្រព័ន្ធទូរស័ព្ទក្រុមហ៊ុន Mobitel ( Cell Card Cash ) ដែលបានជួយសំរួលយ៉ាងច្រើនដល់ប្រជាពលរដ្ឋមានលំនៅដ្ឋាន នៅតំបន់ជាយក្រុងឆ្ងាយៗ ដែលត្រូវចំណាយទាំងថវិកា និងពេលវេលាក្នុងការ ធ្វើដំណើរមកបង់ប្រាក់ថ្លៃទឹក។ |
| **យោបល់** | អតិថិជនអាចទំនាក់ទំនងសួរ និងផ្តល់ព័ត៌មានតាមរយៈ<br>- ទូរស័ព្ទលេខ ០២៣ ៧២៤ ០៤៦ / ០២៣ ៤៣០ ៥៤១/ ០២៣ ៤៣០១៧៩<br>- គេហទំព័រ : www.ppwsa.com.kh<br>- អ៊ីមែល : admin@ppwsa.com.kh |